ភ្នំពេញ , ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣

**ប្រកាសលេខ ០៥៤ សណក.ប្រក**

## ប្រកាស

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
-- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ - ១១ - ៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី
- បានឃើញសារាចរលេខ ០០២ សរណន.គម.គពឃ ចុះថ្ងៃទី ១៨ - ១២ - ១៩៨៩ កំណត់ការងារគ្រប់គ្រងយានជំនិះផ្លូវគោក - ផ្លូវទឹក ។
- បានឃើញប្រកាសលេខ ០៩៣ ប្រក.គម.គពឃ ចុះថ្ងៃទី ១០ - ៣ - ៩២ ស្តីពីការកែប្រែសារាចរណែនាំ អំពីការងារគ្រប់គ្រងយានជំនិះផ្លូវគោក - ផ្លូវទឹក ។
- បានឃើញលិខិតលេខពិសេស ចុះថ្ងៃទី ២២ - ១១ - ៩៣ ស្តីពីការសំរេចរបស់គណៈរដ្ឋមន្ត្រីអោយបន្តការប្រើប្រាស់ ផ្លាកលេខរថយន្តផ្សេងៗ ។
- បានឃើញប្រកាសលេខ ០៤២ សក.ជជ .ប្រក ចុះថ្ងៃទី ០១ - ១២ - ៩៣ ស្តីពីការកំណត់ផ្លាកលេខរថយន្តរបស់សមាជិករដ្ឋសភា ។

## សំរេច

**ប្រការ ១ :** ប្រកាសលេខ ០៩៣ ប្រក.គម.គពឃ ចុះថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ១៩៩២ និង សារាចរលេខ ០០២ សរណន.គម. គពឃ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៨៩ ត្រង់ជំពូកទី ១ ចំណុច ៦ ដែលកំណត់អំពីបញ្ជីការចុះលេខរថយន្ត និង ផ្លាកលេខ យានយន្តគ្រប់ប្រភេទ ត្រូវបានលប់ចោល និងកែប្រែតាម លក្ខខ័ណ្ឌដូចតទៅ ។

**ប្រការ ២ :** ការចុះបញ្ជីការជាថ្មី និង ពណ៌ផ្លាកលេខយានយន្តគ្រប់ប្រភេទត្រូវបានកំណត់ដូចខាងក្រោម

លើកលែងតែរថយន្តរបស់រដ្ឋាភិបាល ៖

១ – សំរាប់យានយន្តធុនតូច និង មធ្យមដែលជារបស់រដ្ឋ

- អក្សរដើម និង លេខ = រាជការ - 0001
- ពណ៌ផ្លាក = ផ្ទៃក្នុងពណ៌បៃតង អក្សរ និង លេខពណ៌ស

២ – សំរាប់រថយន្ត នៃ សមាជិករដ្ឋសភា

- អក្សរដើម និង លេខ = សភ - 001
- ពណ៌ផ្លាក = ផ្ទៃក្នុងពណ៌បៃតង អក្សរ និង លេខពណ៌ស

៣ – សំរាប់យានយន្ត នៃ ព្រះបរមរាជវាំង

- អក្សរដើម និង លេខ = រ៉ 001
- ពណ៌ផ្លាក = ផ្ទៃក្នុងពណ៌ពងក្រសារ អក្សរ និង លេខពណ៌លឿង

៤ – សំរាប់រថយន្តធុនធំ និង គ្រឿងចក្ររបស់រដ្ឋ និង យានយន្តរបស់អង្គភាព សេដ្ឋកិច្ចចំរុះរដ្ឋ

- អក្សរដើម និង លេខ = ភព ៤ - 0001
- ពណ៌ផ្លាក = ផ្ទៃក្នុងពណ៌បៃតង អក្សរ និង លេខពណ៌លឿង

៥ – សំរាប់យានយន្តគ្រប់ប្រភេទ របស់ឯកជន

- អក្សរដើម និង លេខ = OI - 001
- ពណ៌ផ្លាក ផ្ទៃក្នុងពណ៌ផ្ទៃមេឃ
  អក្សរ និង លេខ ពណ៌ស

៩ - សំរាប់រថយន្តឯកជនបរទេស ដែលនាំចូលជាបណ្តោះអាសន្ន

- អក្សរដើម និង លេខ = AT ពីរលេខចុងក្រោយនៃ ឆ្នាំ - ០០០១
  ( ត្រូវប្តូររៀងរាល់ឆ្នាំ )
- ពណ៌ផ្លាក = ផ្ទៃក្នុងពណ៌ស្វាទុំ
  អក្សរ និង លេខពណ៌ស

**ប្រការ ៣** :ចំពោះផ្លាកលេខក្រោយរថយន្តត្រូវដាក់អក្សរដើមនៅពីខាងលើហើយដាក់លេខនៅពីខាងក្រោម ។ រាល់ផ្លាកសញ្ញា និង ដាក់បន្ថែមលេខ ១ និង លេខបន្តបន្ទាប់នៅខាងដើមអក្សរ នៅពេលណាគ្រប់ចំនួនលេខ ៤ ខ្ទង់ខាងក្រោយ ។

**ប្រការ ៤** : ផ្លាកលេខទោចក្រយានយន្ត និង ត្រាក់ទ័រ ម៉ឺម៉ករបស់ឯកជននៅតាមបណ្តាខេត្ត ក្រុង ត្រូវកំណត់លេខ និង ពណ៌លេខដូចប្រការ ២ ខាងលើ ។ អក្សរដើមត្រូវដាក់តាមបណ្តាខេត្ត - ក្រុង ដូចដែលបាន កំណត់ក្នុងសារាចរណែនាំលេខ ០០២ សរណន .គម.គពយ ចុះថ្ងៃទី ១៨ - ១២ - ៨៩ ត្រង់ចំណុច IV ។

**ប្រការ ៥** : លោកអគ្គនាយកនៃក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ហត្ថលេខា និង ត្រា

**អ៊ុំ គៀត**

## អក្សរដើម និង លេខ

ក - ទោចក្រយានយន្ត និង ត្រីចក្រយានយន្ត ---ភព១ - 0000១

ខ - រថយន្តតូច - មធ្យម - ឡានប្រើតាកង់បី ---ភព២ - 000១

គ - រថយន្តធំ ------------------------ភព៣ - 000១

ឃ - គ្រឿងចក្រ និង ត្រាក់ទ័រគ្រប់ប្រភេទ ----ភព៥ - 000១

ង - រ៉ឺម៉កសណ្តោងរថយន្ត ឬ រ៉ឺម៉កត្រាក់ទ័រ --------ភព៦ - 000១

## ពណ៌ផ្លាក

- ផ្ទៃក្នុងពណ៌ស អក្សរ និង លេខ ពណ៌ខ្មៅ សំរាប់យានយន្តប្រើប្រាស់ផ្ទាល់ខ្លួនមិនប្រើប្រាស់ ធ្វើអាជីវកម្ម ។

- ផ្ទៃក្នុងពណ៌ខ្មៅ អក្សរ និង លេខពណ៌ស សំរាប់យានយន្តប្រើប្រាស់ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ឬ ដឹកអ្នកដំណើរ រួមទាំងរថយន្តដាក់ជួលរថយន្តតាក់ស៊ី --- ។

## ៦ - សំរាប់យានយន្តនៃស្ថានទូត និង កុងស៊ុល

- ( រថយន្តរបស់ឯកអគ្គរដ្ឋទូត - CMD -01-001 )

- អក្សរដើម និង លេខ = CD ឬ CC -01-001

- ពណ៌ផ្លាក = ផ្ទៃក្នុងពណ៌លឿង

អក្សរ និង លេខពណ៌ខៀវ

## ៧ - សំរាប់យានយន្តរបស់ភ្នាក់ងារជំនាញ អង្គការសហប្រជាជាតិ

- អក្សរដើម និង លេខ = ONU - 00១

- ពណ៌ផ្លាក = ផ្ទៃក្នុងពណ៌ផ្ទៃមេឃ

អក្សរ និង លេខពណ៌ស

## ៨ - សំរាប់យានយន្តរបស់អង្គការអន្តរជាតិ និង អង្គការមិនមែនរដ្ឋាភិបាល